# មេរៀនទី ១៥៥៖ អេសធើរបានសង្គ្រោះជាតិសាសន៍របស់នាង

នាងអេសធើរ ២-៩

**មេរៀនសម្រាប់គ្រូ** ( *យូធូបលីង* )៖ https://youtu.be/85lqUiNg3PA

**រឿងនៅក្នុងព្រះគម្ពីរសម្រាប់កុមារ៖** https://youtu.be/V7zKXUkPrUQ

**គោលបំណង៖** ព្រះមានផែនការសម្រាប់អ្នក។

**ខគម្ពីរចងចាំ៖ អេភេសូ ២៖១០** *"ដ្បិតយើងរាល់គ្នាជាស្នាដៃ ដែលទ្រង់បង្កើតក្នុងព្រះគ្រីស្ទយេស៊ូវ សំរាប់ការល្អ ដែលព្រះបានរៀបចំជាមុន ឲ្យយើងរាល់គ្នាប្រព្រឹត្តតាម។"*

**ចំរៀង** ( *យូធូបលីង* )៖

១. ព្រះយេស៊ូវគ្រីស្ទជាព្រះអម្ចាស់ https://youtu.be/l-PzUIJ0MVo
២. ព្រះអង្គទ្រង់អស្ចារ្យ https://youtu.be/QXEVqO94wpg
៣. ខ្ញុំនឹងទុកចិត្តទ្រង់ https://youtu.be/WCZlwlstAzc

## ១. អធិស្ឋាន

## ២. ចំរៀង ( *រើសចំរៀងខាងលើ១បទហើយច្រៀងជាមួយសិស្ស* )

## ៣. ល្បែងកំសាន្ត "ខ្លែងឆាបកូនមាន់"



១. បែងចែកកុមារជា ២ក្រុម ឬច្រើនជាងនេះ

២. ក្នុងក្រុមនីមួយៗកុមារត្រូវតោងចង្កេះគ្នា។ អ្នកដែលនៅឈរមុខគេគឺត្រូវតាមចាប់យកអ្នកក្រោយគេនៃក្រុមផ្សេងទៀត ហើយក៏ត្រូវព្យាយាមការពារកូនក្រុមខ្លួនឯងផងដែរ (កន្ទុយក្រោយគេ)

៣. គោលបំណងនៃហ្គេមនេះគឺបង្ហាញពីការព្យាយាមការពារគ្នាទៅវិញទៅមក។ ក្រុមដែលតោងគ្នាមិនជាប់ (នឹងចាញ់ហ្គេមនេះដោយស្វ័យប្រវត្តិ) ហើយក្រុមដែលមានសមាជិករបស់ខ្លួនត្រូវគេចាប់បានក៏ចាញ់ហ្គេមនេះដែរ។

៤. បន្ទាប់ពីលេងល្បែងនេះចប់សូមពន្យល់កុមារថា យើងត្រូវតែការពារគ្នាទៅវិញទៅមកពីសត្រូវរបស់យើង ពីព្រោះព្រះតែងតែមានផែនការដ៏អស្ចារ្យសម្រាប់មនុស្សគ្រប់គ្នា។

## ៤. ការណែនាំមេរៀន

តើអ្នកគិតថាអ្នកអាចផ្លាស់ប្តូរពិភពលោកនេះបានដែរឬទេ? តើអ្នកគិតថាអ្នកអាចបង្កើតឲ្យមានឥទ្ធិពលដ៏ធំសម្រាប់ពិភពលោកនេះដែរឬទេ? តើអ្នកគិតថាបំណងប្រាថ្នាដ៏ធំបំផុតនៅក្នុងជីវិតរបស់អ្នកគឺជាអ្វី? ហេតុអ្វីបានជាព្រះបង្កើតអ្នកឡើង?ថ្ងៃនេះយើងនឹងរៀនពីផែនការរបស់ព្រះដែលមានចំពោះក្មេងស្រីធម្មតាម្នាក់នៅក្នុងព្រះគម្ពីរ។

## ៥. រឿងនៅក្នុងព្រះគម្ពីរ

ជាយូរលង់ណាស់មកហើយនៅក្នុងទីក្រុងពើស៊ី គឺមានស្តេចដ៏កំសត់ម្នាក់ដែលមានព្រះនាមថា អ័ហាស៊ូរុស។ ទ្រង់គឺនៅម្នាក់ឯងដោយសារតែទ្រង់មិនមានអគ្គមហេសីនោះទេ។ ដូច្នេះទ្រង់ក៏បានប្រាប់ឲ្យអ្នកបម្រើរបស់ទ្រង់ ចេញទៅស្វែងរកស្ត្រីដែលមានសម្រស់ស្អាតដាច់គេតាមតែអាចធ្វើទៅបាន។ អ្នកបម្រើបានស្វែងរកហើយរកទៀត រហូតបានរកឃើញក្មេងស្រីម្នាក់ដែលមានឈ្មោះថា អេសធើរ។

នាងត្រូវបានគេចាប់យកទៅទីក្រុង ដើម្បីឲ្យដឹងថាស្តេចចង់បាននាងធ្វើជាអគ្គមហេសីឬអត់។ ពីមុនអេស-ធើរបានចាកចេញពីផ្ទះរបស់របស់នាង និងផ្ទះរបស់ជីដូនមួយរបស់នាង, ម៉ាដេកាយ បានប្រាប់នាងថា

មិនត្រូវប្រាប់នរណាម្នាក់ថានាងជាជនជាតិយូដានោះទេ ដោយព្រោះតែមានមនុស្សជាច្រើនមិនចូលចិត្តសាសន៍យូដានោះឡើយ។ ស្តេចគឺពេញចិត្តនឹងអេសធើរជាខ្លាំង ហើយទ្រង់បានយកនាងធ្វើជាអគ្គមហេសីរបស់ព្រះអង្គទៀតផង។

ស្តេចក៏មានអ្នកជនិតរបស់ទ្រង់ផងដែរ គឺជាម្នាក់ដែលមានអំណាចជិតស្មើនឹងព្រះអង្គផងដែរ។ គាត់មានឈ្មោះថា ហាម៉ាន។ ហាម៉ាន មិនចូលចិត្តសាសន៍យូដានោះទេ។ គាត់ល្ងីល្ងើ និងអាក្រក់ខ្លាំងណាស់។ គាត់បានបញ្ចុះបញ្ចូលឲ្យស្តេចបង្កើតច្បាប់ដ៏អាក្រក់មួយ។ នៅក្នុងច្បាប់នោះបាននិយាយថា នៅថ្ងៃពិសេស ជនជាតិយូដាត្រូវតែសម្លាប់ទាំងអស់។

នៅពេលដែល ម៉ាដេកាយ បានរៀនពីច្បាប់ថ្មី គាត់ក៏ចាប់យំឡើង - ស្រែកយំខ្លាំងៗ។ គាត់គឺពិតជាមានការសោកសៅខ្លាំងណាស់ ហើយថែមទាំងហែកសំលៀកបំពាក់ខ្លួនទៀតផង។ បន្ទាប់មកគាត់ក៏បានផ្ញើសារទៅកាន់ជីដូនមួយរបស់គាត់ គឺម្ចាស់ក្សត្រី។ គាត់បានប្រាប់ទៅម្ចាស់ក្សត្រី អេសធើរឲ្យទៅទូលសុំឲ្យស្តេចប្តូរច្បាប់នោះចេញ ដើម្បីជួយសង្គ្រោះសាសន៍យូដា។ ប៉ុន្តែគឺមិនមាននរណាម្នាក់ត្រូវបានអនុញ្ញាតឲ្យចូលទៅគាល់ស្តេចបាននោះទេ ប្រសិនបើស្តេចមិនបានកោះហៅឲ្យចូលគាល់នោះ។ ម្ចាស់ក្សត្រីអេសធើរ មានការភ័យខ្លាចជាខ្លាំង។ ប៉ុន្តែម៉ាដេកាយ បានប្រាប់មិនឲ្យនាងមានការភ័យខ្លាចនោះទេ។ គាត់បាននិយាយថា ព្រះបានអនុញ្ញាតឲ្យនាងក្លាយជាម្ចាស់ក្សត្រី ដូច្នេះនាងត្រូវតែជួយសង្គ្រោះដល់សាសន៍យូដា។ ដូច្នេះ ម្ចាស់ក្សត្រីអេសធើរ ព្រមទាំងអ្នកបម្រើរបស់នាង និងជនជាតិយូដាទាំងអស់បានអធិស្ឋានតមរយៈ ពេលបីថ្ងៃ។

បន្ទាប់មកម្ចាស់ក្សត្រីអេសធើរបានដើរទៅកាន់ព្រះរាជវាំងខាងក្នុង។ តើមានអ្វីកើតឡើង? ប្រសិនបើទ្រង់កាន់ដំបងមាស នោះនាងអាចរស់បន្ត។ ប៉ុន្តែប្រសិនបើទ្រង់មិនកាន់ដំបងទេនោះនាងនឹងស្លាប់។ នៅពេលដែលអេសធើរបើកទ្វារចូលទៅ ស្តេចគឺកំពុងតែកាន់ដំបងមាសរបស់ព្រះអង្គ។ ស្តេចបានសន្យាថាទ្រង់នឹងប្រទានឲ្យគ្រប់យ៉ាងដែលនាងសុំ។ នាងបានអញ្ជើញស្តេច និងហាម៉ានយាងទៅសោយអាហារ។ នៅក្នុងពេលសោយអាហារ នាងបានទូលប្រាប់ស្តេចពីផែនការដ៏អាក្រក់ដែលហាម៉ាន ចង់សម្លាប់ជនជាតិយូដា។ ស្តេចមានការខ្ញាល់ជាខ្លាំង។ ហាម៉ានក៏ត្រូវបានសម្លាប់ ហើយម៉ាដេកាយក៏បានក្លាយជាអ្នកជំនិតរបស់ស្តេចជំនួសវិញ ហើយជនជាតិយូដាទាំងអស់ក៏ត្រូវបានសង្គ្រោះផងដែរ។

ព្រះមានផែនការសម្រាប់ម្ចាស់ក្សត្រីអេសធើរ។ នៅពេលដែលនាងដើរតាមផែនការរបស់ព្រះ ជនជាតិយូដាទាំងអស់ក៏ត្រូវបានសង្គ្រោះ។ ព្រះបានបង្កើតយើងទាំងអស់គ្នាមក តាមផែនការរបស់ព្រះអង្គ ហើយទ្រង់គឺមានការងារសម្រាប់យើងម្នាក់ៗក្នុងការបំពេញផងដែរ។ ព្រះគម្ពីរបានប្រាប់យើងថា យើងបានបង្កើតឡើងដើម្បីធ្វើកិច្ចការក៏ល្អ។ ហើយព្រះបានសន្យាថាទ្រង់នឹងគង់ជាមួយ និងជួយដល់យើងក្នុងការ បំពេញកិច្ចការទាំងអស់នោះ។ ពួកយើងគឺបម្រើព្រះដ៏ល្អ និងមានព្រះចេស្តា ដែលទ្រង់បានបង្កើតផែនការដ៏អស្ចារ្យសម្រាប់ប្រជារាស្ត្ររបស់ព្រះអង្គ។

## ៦. សំនួរពិភាក្សា

១. តើមូលហេតុអ្វីបានស្តេចអ័ហាស៊ូរុសក្រៀមក្រំ? *(ពីព្រោះទ្រង់មិនមានអគ្គមហេសី)*

២. តើនរណាដែលក្លាយជាម្ចាស់ក្សត្របន្ទាប់របស់ស្តេច អ័ហាស៊ូរុស? *(អេសធើរ)*

៣. តើផែនការដ៏អាក្រក់របស់ហាម៉ានគឺជាអ្វី? *(សម្លាប់ជនជាតិយូដាទាំងអស់)*

៤. តើម្ចាស់ក្សត្រីអេសធើរ គួរធ្វើអ្វីខ្លះ ដើម្បីសង្គ្រោះសាសន៍យូដា? *(នាងគួរតែទៅជួបស្តេចបើទោះបីជាស្តេចមិនបានអញ្ជើញនាង បើទោះបីជានាងអាចមានទោសដល់ស្លាប់ដ៏ដោយ)*

៥. តើព្រះបានប្រើអេសធើរដោយរបៀបណា? *(នាងបានសង្គ្រោះជនជាតិយូដា)*

៦. តើអ្នកគិតថាព្រះមានផែនការអ្វីសម្រាប់អ្នក? *(ទុកឲ្យកុមារជាអ្នកឆ្លើយ)*

## ៧. ល្បែងកំសាន្ត «ជញ្ជូនក្រូចឆ្មាបន្តគ្នា»

សម្ភារៈដែលត្រូវការ៖ ស្លាបព្រា ក្រូឆ្មារ៣០ និងកញ្ចែង៦

១.ចែកកុមារជាបីក្រុម ហើយដាក់កញ្ចែង នៅពីមុន និងពីក្រោយ

២. ដាក់ក្រូចឆ្មារ ១០ នៅក្នុង កញ្ចែងខាងមុន ហើយឲ្យស្លាបព្រា ទៅកុមារនីមួយៗ




៣. ឲ្យកុមារទីមួយដែលឈរជាជួរនោះ ព្យាយាមយកក្រូចឆ្មារ ពីកញ្ចែងដោយប្រើបានតែស្លាបព្រាតែប៉ុណ្ណោះ (មិនអាចប្រើដៃបានទេ) ហើយបន្ទាប់មកបញ្ជូនក្រូចឆ្មារនោះទៅកុមារបន្ទាប់។បន្តបញ្ជូនក្រូចនោះ រហូតទៅដល់កុមារចុងក្រោយ។ ប្រសិនក្រូចនោះធ្លាប់នោះគេមិនអាចរើសបាននោះទេ។

៤. ក្រុមណាដែលអាចជញ្ជូនក្រូចឆ្មារបានច្រើជាងគេក្រុមនោះជាអ្នកឈ្នះ។

៥. បន្ទាប់ពីលេងល្បែងនេះចប់សូមពន្យល់កុមារថា ព្រះបានប្រើអេសធើរ ដើម្បីការពារដល់ជនជាតិយូដា។ ក៏ដូចគ្នានេះដែរ សម្រាប់ល្បែងនេះអ្នកបានការពារដល់ក្រូចឆ្មារ មិនឲ្យធ្លាក់។ នៅក្នុងជីវិតរស់នៅព្រះបានមានផែនការដ៏អស្ចារ្យសម្រាប់យើងរាល់គ្នា។ហើយព្រះអង្គនឹ ងជួយអ្នកឲ្យបំពេញការហៅនោះ ដូចជាទ្រង់បានជួយ ដល់អេសធើរអីចឹងដែរ។

## ៨. ខគម្ពីរចងចាំ

**អេភេសូ ២៖១០** *"ដ្បិតយើងរាល់គ្នាជាស្នាដៃ ដែលទ្រង់បង្កើតក្នុងព្រះគ្រីស្ទយេស៊ូវ សំរាប់ការល្អដែលព្រះបានរៀបចំជាមុន ឲ្យយើងរាល់គ្នាប្រព្រឹត្តតាម។"*

## ៩. ហត្ថកម្ម **"អេសធើរសង្គ្រោះជាតិសាសន៍របស់នាង"**

សម្ភារៈដែលត្រូវការ៖ ព្រីនក្រដាសហត្ថកម្ម កូល័រ កន្ត្រៃ និងការបិត

១. ព្រីនក្រដាសហត្ថកម្មរូបមកុដ ឲ្យកុមារម្នាក់មួយសន្លឹកហើយឲ្យពួកគេតុបតែងវា

២. កាត់រូបមកុដ និងរូបបន្ទាត់ពីរនោះចេញមក រួចបិតភ្ជាប់វាជាមួយគ្នា ដើម្បីធ្វើជាមកុដមួយ។

៣. សូមពន្យល់កុមារថា បើទោះបីជាយើងគ្រាន់តែជាមនុស្សធម្មតាក៏ដោយ ព្រះចង់ឲ្យយើងធ្វើនូវរឿងអស្ចារ្យនៅថ្ងៃអនាគត! សូមឲ្យយើងបានចងចាំពីការសន្យារបស់ព្រះអង្គ និងស្តាប់បង្គាប់ទ្រង់ជានិច្ច។

## ១០. ចំរៀង *(រើសចំរៀងខាងលើ១បទហើយច្រៀងជាមួយសិស្ស)*

## ១១. អធិស្ឋាន

**ការថ្វាយបង្គំសំរាប់គ្រូ៖ (សូមអាន ហើយអធិស្ឋានមុនពេលចាប់ផ្តើមបង្រៀន)**
អ្នកដើរតាមព្រះយេស៊ូវ ត្រូវបានដើរតួខុសៗគ្នានៅក្នុងជីវិតរស់នៅប្រចាំថ្ងៃ។ សូមអានព្រះគម្ពីរ នាងអេសធើរ ៤៖១៤ សារឡើងវិញ។ ផ្អែកទៅលើអត្ថបទនេះ តើនឹងមានរឿងអ្វីកើតឡើង ប្រសិនបើយើងបដិសេធមិនដើរតាមផែនការរបស់ព្រះ? តើនឹងមានរឿងអ្វីកើតឡើងចំពោះយើង? ហេតុអ្វីបានជាព្រះបង្ហាញយើងពី តួនាទីជាក់លាក់ និងពេលវេលាជាក់លាក់នោះ? សូមសញ្ជឹងគិតពីបីសំណួរខាងលើនេះ? បន្ទាប់មកសូមសូមអធិស្ឋានបែបនេះ៖ "ឲ្យព្រះយេស៊ូវអើយ សូមទ្រង់បង្ហាញខ្ញុំឲ្យចូលរួមក្នុងពន្ធកិច្ចរបស់ព្រះអង្គ ដែលមានសម្រាប់ខ្ញុំ ហើយយើងខ្ញុំសូមអរព្រះគុណព្រះអង្គដែលបាន ដតែងតែជួយឲ្យរឿងគ្រប់យ៉ាងបានទទួលនូវលទ្ធផលល្អ នូវរាល់គ្រប់កិច្ចការដែលទ្រង់បានដាក់ឲ្យខ្ញុំធ្វើ។"


បិតទីនេះ
បិតទីនេះ